Sipar

បោះពុម្ពលើកទី៦

ជុត ខៃ

# ក្មេងវត្ត សម័យបារាំង



# វត្តថ្មគោល

### កម្ទេចព្រះមួយអង្គ ចំណេញស៊ីម៉ងត៍មួយបាវៗ

(ខ្មែរក្រហម)

ឆ្នាំ១៩៤៧...

ថ្ងៃមួយនោះ ពូថា បារាំងដើរចាប់ក្មេងឃ្វាលគោឱ្យទៅរៀននៅសាលាបារាំង ដោយសារសិស្សចេះតែរត់លួនមិនចង់រៀនសូត្រសោះៗ



ក្រោយពីបានព័ត៌មាននេះភ្លាម ឪពុករបស់អាឆែក៏បញ្ជូនវាឱ្យទៅនៅវត្តថ្មគោលចម្ងាយប្រហែល៧គមពីផ្សារកំពង់ចាម និង១គមពីមាត់ទន្លេមេគង្គៗ

នៅក្បែររបងវត្ត គេឃើញមានកូនសំណង់តូចមួយ(មិនខុសពីខ្ទមអ្នកតាឡើយ)ធ្វើអំពីឫស្សី ដំបូលប្រក់ស្បូវៗ សំណង់នេះ គេធ្វើឡើងសម្រាប់ការពារថ្មមួយដុំកុំឱ្យត្រូវទឹកភ្លៀងឬកម្តៅថ្ងៃៗ ថ្មនោះផុះផុតពីដី មានកម្ពស់ប្រហែលជាមួយម៉ែត្រៗ ចំណែកឯក្បាលវាស្រួច មិនខុសពីក្បាលដែកគោលប៉ុន្មានទេៗ

អ្នកភូមិតែងតែគោរពថ្មនោះ មិនខុសពីគេគោរពអ្នកតាឡើយ។ ដោយសារថ្មនេះហើយ ទើបបានជាគេឱ្យឈ្មោះវត្តនេះថាជាវត្តថ្មគោល។



វត្តនេះជាវត្តមួយគួរឱ្យចម្លែក ព្រោះលោកសង្ឃដែលគង់នៅទីនោះ ចែកជាពីរគណៈ«អែវម៉ែ» និង«អេវម៉េ» មានន័យថា ធម៌បុរាណ និងធម៌សម័យ ឬមានន័យម្យ៉ាងទៀតថា «ថ្នេរសំប៉ែត» និង«ថ្នេរមូល»។ បានជាគេហៅថា ថ្នេរសំប៉ែត ព្រោះស្បង់ចីពររបស់លោកសង្ឃធម៌បុរាណមានថ្នេរសំប៉ែត រីឯស្បង់ចីពរលោកសង្ឃធម៌សម័យមានថ្នេរមូល។ មានលក្ខណៈពីរទៀតដែលខុសគ្នា។ ខាងបុរាណ លោកនេនយកស្បង់ចីពរមកគ្រង(យកស្បង់ចីពរមកពាក់នៅលើស្មា រួចយកខ្សែក្រវាត់សំពត់មកចងនៅលើចង្កេះ) រីឯខាងសម័យ លោកនេនឃ្លុំ(យកស្បង់ចីពរមករុំជុំខ្លួនជុំជិតខាងលើឃើញតែកនិងព្រះកេស ខាងក្រោមឃើញត្រឹមកំភួនជើងចុះ) នៅពេលលោកនិមន្តទៅបិណ្ឌបាត ឬទៅណាម្ដងៗ។

វត្តមួយសង្ក្រាជ(១)ពីរ មិនខុសពីភ្នំមួយមានខ្លាពីរទេ។ ដល់អីចឹងទៅលោកសង្ឃក៏មិនសូវត្រូវគ្នា ក្មេងលោកក៏ឈ្លោះគ្នាមិនស្វាង។ មិនត្រឹមតែមនុស្សឈ្លោះគ្នា អាឆ្កែក៏មិនត្រូវគ្នាដែរ។ ឆ្កែខាង«អែវម៉ែ»ឃើញឆ្កែខាង«អេវម៉េ»មិនបានទេ គឺគ្រហឹមខាំគ្នាយកស្លាប់យករស់តែម្ដង។

លោកគ្រូសង្ក្រាជខាងធម៌បុរាណមាននាមថា លោកគ្រូអាចារ្យហៃ។

ចំណែកចៅអធិការខាងធម៌សម័យមានព្រះនាមថា លោកគ្រូអាចារ្យចៅ។ លោកគ្រូសង្គ្រាជទាំងពីរអង្គមានលោកគ្រូសូត្រមួយម្នាក់ៗ ការដែលគួរឱ្យកត់សម្គាល់នោះ គឺលោកគ្រូសូត្រទាំងពីរគណៈមានព្រះនេត្រខ្វាក់ដូចៗគ្នា។

អាឆៃ និងខ្ញុំនៅកុដិលោកគ្រូអាចារ្យចៅជាមួយគ្នា។ ក្មេងវត្តខាងអាចារ្យចៅមានទាំងអស់ប្រហែល៣០នាក់។ អាមាឌធំៗ ក្បាលកញ្ចាស់ដូចអាឆៃមាន៥ ឬ៦នាក់។ នៅពេលភ្ជុំបិណ្ឌម្តងៗ អាឆៃតែងតែនាំក្មេងវត្តអើតករហាបនៅលើកុដិដើម្បីអ៊ុតមើលអ្នកទូលនំអន្សម ផ្លែឈើ



ម្ហូបម្ហាមកប្រគេនលោក ថាតើអ្នកទាំងអស់នោះទៅកុដិអាចារ្យចៅ ឬអាចារ្យហៃ។ បើឃើញអ្នកធ្វើបុណ្យដើរសំដៅមកកុដិអាចារ្យចៅ អាឆៃ និងគូកនវាសប្បាយរីករាយណាស់។ តែបើឃើញឧបាសក ឧបាសិកាណាដើរសំដៅទៅកុដិអាចារ្យហៃ វាប្រទេចផ្ដាសាថា ជាពួកអា«អ៊ែវម៉ែ» បុរាណចាស់គំរិល។

នៅខាងលោកធម៌សម័យ គេឃើញមានកុដិធំៗពីរ គឺកុដិលោកគ្រូសង្ឃរាជ និងលោកគ្រូសូត្រ។ ក្រៅពីកុដិ គេឃើញមានតូប៥៦ទៀត។ កុដិ និងតូបទាំងនោះសង់អំពីឈើប្រក់ក្បឿង។ លោកសង្ឃខាងសម័យ



Sipar

បោះពុម្ពលើកទី4

ជុត ខៃ

# ក្មេង
# សាលាបារាំង



អក្សរសិល្ប៍យុវវ័យ
ចាប់ពី 12 ឆ្នាំ

# ជំពូក២

# សាលាប្រុស

សាលាប្រុស(école de garçons)ស្ថិតនៅចម្ងាយប្រហែលជា ៥០០ម៉ែត្រពីសាលាស្រី(école de filles)។ សាលាទាំងពីរនេះ ស្ថាបនាឡើងនៅមុនសង្គ្រាមលោកលើកទី២(១៩៣៩-៤៥)។

ព័ទ្ធទៅដោយរបងថ្មយ៉ាងរឹងមាំ សាលាប្រុសមានអគារថ្មបួនខ្នង និងឈើមួយខ្នង ហើយសង់ឡើងនៅលើដីភាបបួនជ្រុងទ្រវែងជាប់ និងភូមិមេម៉ាយ។ នៅមុខសាលា គឺវាលទាត់បាល់ បន្ទាប់មកទៀត គេឃើញអគារថ្មពីរ ធំមួយ តូចមួយ។ អគារធំជាកន្លែងទទួលក្មេង សាលាដែលបានទទួលអាហារូបករណ៍ចាប់ពីថ្នាក់មធ្យមដ្ឋានទី១ (Cours moyen 1ère année)រហូតដល់ថ្នាក់ឧត្តមដ្ឋាន(Cours supérieur)។ ក្មេងទាំងនេះមានចំនួនប្រហែលជាង៥០នាក់ ហើយ ច្រើនតែមកពីស្រុកនានាក្នុងខេត្តកំពង់ចាម ដែលមានថ្នាក់រៀនត្រឹម អាទិកដ្ឋាន(Cours élémentaire)(៤)។ វិន័យ និងការអប់រំក្មេង ទាំងនេះមានសភាពតឹងតែង មិនខុសពីវិន័យកុមារយោធិន(៥)នោះ ឡើយ។ ដេក ដើរ អង្គុយ ឬចេញទៅក្រៅសាលាសុទ្ធតែមានច្បាប់ ទម្លាប់ទាំងអស់។ ចំណែកអគារតូច គឺជាអធិការដ្ឋានបឋមសិក្សា

ក្រុងកំពង់ចាម។

នៅតាមចិញ្ចើមថ្នល់កាត់មុខទ្វារសាលាប្រុស គេឃើញមានដើមអម្ពិលបារាំងដុះជាជួរ។ ដើមឈើទាំងនេះបែកមែកសាខា ហើយចោលម្លប់យ៉ាងត្រឈឹងត្រឈៃទៅលើផ្លូវថ្នល់និងអគារសាលា។ នៅមុនពេលចូលរៀនព្រឹកល្ងាច ឬពេលក្មេងសម្រាក សភាពគ្អឹកអរខ្ញៀវខ្ញារតែងតែមានជានិច្ចនៅក្រោមដើមឈើ ព្រោះក្មេងជាច្រើននាក់នាំគ្នាចោមរោមអ្នកលក់នំបញ្ចុក បបរត្រី ល្ហុងញាំកំពឹស អន្សមអាំង នំបំពង-ល-និង-ល-។

សាលាប្រុសគ្មានសិស្សស្រីមែន តែមានគ្រូស្រី គឺអ្នកគ្រូធីម៉ាយ និងអ្នកគ្រូស៊ីណាង។ អ្នកគ្រូទី១មានដើមកំណើតជាយួនកើតនៅស្រុកខ្មែរ។ ឪពុកគាត់ធ្វើរាជការបម្រើអាណានិគមបារាំងតាំងពីអើយមកម្ល៉េះ។ ចំណែកប្ដីគាត់ធ្វើការនៅក្រសួងសុរិយោដី ដែលខ្មែរយើងចូលចិត្តហៅលេងសើចថា ក្រសួងសុរិយោជី។ រីឯពួកសិស្សខិលវ៉ានាំគ្នាហៅគាត់ថា«អ្នកគ្រូយាយជី»។ អ្នកគ្រូទី២គឺជាខ្មែរសុទ្ធសាធតែម្ដង។

បើនិយាយពីសម្លៀកបំពាក់ អ្នកគ្រូទាំងពីរស្លៀកពាក់ខុសគ្នាស្រឡះ។ អ្នកគ្រូធីម៉ាយ សាច់សទ្រលុកដូចបណ្ដូលចេកពងមាន់។ នៅពេលមកបង្រៀន គាត់ពាក់អាវផាយព្រែពណ៌ខ្មៅ។ នេះជាលក្ខណៈមួយប្លែកបន្តិច ព្រោះស្រីយួនច្រើនពាក់អាវផាយពណ៌ស។ ចំណែកអ្នកគ្រូស៊ីណាង ក្រមុំចាស់ មានមាឌធំខ្ពស់ ស្បែកខ្មៅព្រឹក ហើយស៊ីស្លារៀងរាល់ថ្ងៃ ដែលជាហេតុធ្វើឱ្យបបូរមាត់គាត់ក្រហម

ផានិច្ច ដោយមិនចាំបាច់«ម៉ាគីយេ»(maquiller)ឡើយ។ គាត់ស៊ីស្លាម៉ែន តែធ្មេញគាត់មិនខ្មៅដូចធ្មេញយួនហ្មៀនោះទេ ព្រោះក្រោយពីស៊ីស្លារួច គាត់យកសំបកផ្លែស្លាមកដុសធ្មេញយ៉ាងហោចណាស់ពីរបីដងក្នុងមួយថ្ងៃ។ អ្នកគ្រូស៊ីណាងអាយុជិត៥០ឆ្នាំហើយ។ កាលពីប៉ុន្មានឆ្នាំមុន មានស្មៀនសាលាខេត្តម្នាក់មកស្ដីដណ្ដឹងគាត់ តែគាត់មិនព្រម ព្រោះសាម៉ីខ្លួនសុំឱ្យគាត់ឈប់ស៊ីស្លានៅពេលការរួច។

អ្នកគ្រូស៊ីណាងមានឡានរ៉ឺណូ(Renault)ពណ៌ខ្មៅមួយ ដែលជំនាន់នោះខ្មែរយើងនិយមហៅថា ឡានផ្ចិត។ អ្នកគ្រូយើងថែឡានមិនខុសពីម្ដាយថែកូនខ្ចីនោះទេ គឺព្រឹកជូតល្ងាចជូត។ ជូតរួចហើយគាត់យកក្រណាត់មកគ្របវា ហាក់ដូចជាខ្លាចឡានរងា ឬខ្លាចគេឃើញយានគាត់។ យូរៗគាត់បើកឡានមកសាលាម្ដង។ នៅពេលគាត់បើកឡានមកសាលាម្ដងៗ ក្មេងៗនាំគ្នាចោមរោមមើលវា មិនខុសពីសត្វរុយរោមលាមក។

អ្នកគ្រូទាំងពីរនេះឆ្នាស និងកាចដូចៗគ្នា។ គាត់ចូលចិត្តក្ដិច ឬញ៉ិងស្លឹកត្រចៀកសិស្ស។ តែវិធីទាំងពីរមុខនេះមិនគ្រប់គ្រាន់ទេចំពោះគាត់ ព្រោះក្រោយពីក្ដិច គាត់ប្រើរំពាត់ផ្ដៅទៀត។ អ្នកគ្រូ ធីម៉ាយ បង្រៀនថ្នាក់ឧត្ដមដ្ឋាន«ក»(Cours supérieur A) ចំណែកអ្នកគ្រូស៊ីណាង ថ្នាក់ឧត្ដមដ្ឋាន«ខ»(Cours supérieur B)។

សាលាប្រុសមាន១៦ថ្នាក់ ដូចនេះគ្រូក៏មាន១៦នាក់ដែរ។ ក្នុងចំណោមគ្រូទាំង១៦នេះ មានតែគ្រូម្នាក់គត់ដែលស្លូត ហើយមិនចេះវាយសិស្ស គឺលោកគ្រូសោម។ លោកគ្រូសោមមិនមែនត្រឹម

តែស្លូតទេ គាត់ថែមទាំងចេះកំប្លែងទៅទៀត ដែលជាហេតុធ្វើឱ្យសិស្សស្រឡាញ់ និងចូលចិត្តរៀនជាមួយគាត់ខ្លាំងណាស់។ គាត់បង្រៀននៅថ្នាក់មធ្យមដ្ឋានទី១(Cours moyen 1ère année)។ គាត់មានវ័យចំណាស់ជាងគ្រូឯទៀតៗ ហើយចូលធ្វើការនៅក្រសួងសិក្សាធិការជាតិ មួយឆ្នាំពីរមុនសង្គ្រាមលោកលើកទី២។

*

*   *

បរិវេសនកាលឆ្នាំ១៩៥០។

គួរកត់សម្គាល់ថា នៅជំនាន់នោះ សិស្សចាប់រៀនភាសាបារាំងតាំងពីថ្នាក់កុមារដ្ឋាន(Cours enfantin)។

នៅព្រឹកថ្ងៃចូលរៀន ឪពុកម្ដាយសិស្សព្រមទាំងក្មេងៗជាច្រើននាក់នាំគ្នាឈរកកកុញនៅក្នុងទីធ្លាសាលា។ ក្រោយពីឮស្គរជួងដំបូងមក គ្រូ សិស្ស និងឪពុកម្ដាយសិស្សនាំគ្នាគោរពទង់ជាតិនៅមុខសួនច្បារ។ ក្រោយពីគោរពទង់ជាតិហើយ សិស្សនាំគ្នាមកតម្រៀបជួរនៅមុខថ្នាក់រៀងៗខ្លួន។ ចាប់ពីថ្នាក់អាទិកដ្ឋានរហូតដល់ថ្នាក់ឧត្តមដ្ឋាន សិស្សមានបួនផ្នែក៖ សិស្សដេកស៊ីបាយ«បូក្ស» (bourse) នៅក្នុងសាលា(internes)[៦] សិស្សបានអាហារូបករណ៍ជាលុយ (externes)[៧] សិស្សជាកុមារយោធិន[៨] និងសិស្សធម្មតា។

នៅថ្នាក់អ្នកគ្រូធីម៉ាយ ក៏ដូចជាថ្នាក់អ្នកគ្រូស៊ីណាង សិស្សម្នាក់ៗ